ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# សេចក្តីអំពាវនាវ

## របស់សម្តេច ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

***** + *****

ថ្ងៃ អាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ស្អែកនេះ គឺជាទិវាប្រវត្តិសាស្ត្រ ដែលប្រជាពលរដ្ឋកម្ពុជា ទូទាំងប្រទេសប្រារព្ធការបោះឆ្នោតជ្រើសរើសសមាជិក សមាជិការដ្ឋសភា ក្នុងគោលដៅបង្កើតឡើងនូវ រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ ដើម្បីអនុវត្តនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ដោយឈរលើមូលដ្ឋាន នៃការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ប្រជាជនកម្ពុជាយើង ។

ក្នុងគោលបំណងពង្រឹងស្ថិរភាព សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និង ជៀសវាងការប្រើអំពើហិង្សា ផ្សេងៗជាយថាហេតុ និង ជាពិសេស ដើម្បីធានាឱ្យបានថា ការបោះឆ្នោតនេះ នឹងប្រព្រឹត្តទៅនៅក្នុងភាពត្រឹមត្រូវ ដោយសេរី និង យុត្តិធម៌នោះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់ជនរួមជាតិទាំងអស់ សូមអញ្ជើញទៅបោះឆ្នោត ឱ្យបានគ្រប់ៗគ្នា ជូនគណៈបក្សនយោបាយណាដែលខ្លួនស្រឡាញ់ និង មានជំនឿទុកចិត្ត ហើយសូមរក្សាឱ្យបាន នូវភាពស្ងៀមស្ងាត់ សេចក្តីថ្លៃថ្នូរ ការចេះយោគយល់អធ្យាស្រ័យឱ្យគ្នា ចូលរួមជួយថែរក្សាសណ្តាប់ធ្នាប់សង្គម និង សូមកុំពិសាស្រា ឬ ភេសជ្ជៈស្រវឹង នៅក្នុងថ្ងៃបោះឆ្នោត នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ នេះ ។

រាជរដ្ឋាភិបាល សង្ឃឹមថា ជនរួមជាតិទាំងអស់ នឹងចូលរួមចំណែកអនុវត្តតាមសេចក្តីអំពាវនាវនេះ ដោយក្តីសោមនស្សរីករាយ និង ស្មារតីទទួលខុសត្រូវខ្ពស់ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន